**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ :** ១២៩ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពី

## បែបបទនិងនីតិវិធីនៃការស្នើសុំនិងវាយតម្លៃក្នុងការផ្តល់គោរមងារឧកញ៉ា និងការបញ្ចប់គោរមងារឧកញ៉ា

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨២៣/១៩៨១ ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ២០២៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០២២៤/២០៥ ចុះថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០២៤ ស្តីពីការតែងតាំងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១០២៣/២២៥០ ចុះថ្ងៃទី១១ ខែតុលា ឆ្នាំ២០២៣ ស្តីពីគោរមងារឧកញ៉ា
- បានឃើញអនុក្រឹត្យលេខ១១៦ អនក្រ.បក ចុះថ្ងៃទី៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃទីស្តីការគណៈរដ្ឋមន្ត្រី
- បានឃើញអនុក្រឹត្យលេខ៣០៨ អនក្រ.បក ចុះថ្ងៃទី៦ ខែតុលា ឆ្នាំ២០២៣ ស្តីពីការដំឡើងនាយកដ្ឋានឥស្សរិយយស ទៅជាអគ្គនាយកដ្ឋានឥស្សរិយយសនិងគោរមងារ
- យោងតាមតម្រូវការចាំបាច់របស់រាជរដ្ឋាភិបាល

## សម្រេច

## ជំពូកទី១

## បទប្បញ្ញត្តិទូទៅ

**មាត្រា១ .-**

អនុក្រឹត្យនេះកំណត់អំពីបែបបទនិងនីតិវិធីនៃការស្នើសុំនិងការវាយតម្លៃក្នុងការផ្តល់គោរមងារឧកញ៉ាទំហំទឹកប្រាក់នៃអំណោយនិងវិភាគទាន របកគំហើញបច្ចេកវិទ្យាថ្មីៗឬស្នាដៃពិសេស ព្រមទាំងបែបបទនិងនីតិវិធីនៃការបញ្ចប់គោរមងារឧកញ៉ា ដើម្បីធានាបាននូវសេចក្តីថ្លៃថ្នូរ ទំនៀមទម្លាប់ ប្រពៃណីល្អ សណ្តាប់ធ្នាប់សាធារណៈ សន្តិសុខជាតិ និងការអភិវឌ្ឍសេដ្ឋកិច្ចសង្គម។

## ជំពូកទី២
## បែបបទនិងនីតិវិធីនៃការស្នើសុំផ្ដល់គោរមងារឧកញ៉ា

**មាត្រា២ .-**

ក្រសួង ស្ថាប័ន និងសមាគមឧកញ៉ាកម្ពុជា អាចស្នើសុំការផ្ដល់គោរមងារឧកញ៉ាដល់រូបវន្តបុគ្គលជាប្រជាពលរដ្ឋខ្មែរដែលមានគុណបំណាច់ក្នុងការចូលរួមអភិវឌ្ឍនិងកសាងជាតិ។

ក្រសួង ស្ថាប័ន និងសមាគមឧកញ៉ាកម្ពុជា ត្រូវធ្វើការពិនិត្យវាយតម្លៃបេក្ខភាពស្នើសុំគោរមងារ ដោយផ្អែកតាមគុណសម្បត្តិ គុណបំណាច់ លក្ខខណ្ឌ និងលក្ខណសម្បត្តិរបស់រូបវន្តបុគ្គលជាប្រជាពលរដ្ឋខ្មែរ មុនស្នើសុំគោរមងារឧកញ៉ាដល់រូបវន្តបុគ្គលណាម្នាក់ ដោយអនុលោមតាមបទប្បញ្ញត្តិនៃព្រះរាជក្រឹត្យលេខ នស/រកត/១០២៣/២២៥០ ចុះថ្ងៃទី១១ ខែតុលា ឆ្នាំ២០២៣ ស្ដីពីគោរមងារឧកញ៉ា និងអនុក្រឹត្យនេះ។

**មាត្រា៣ .-**

ការស្នើសុំផ្ដល់គោរមងារឧកញ៉ា ត្រូវភ្ជាប់មកជាមួយនូវពាក្យស្នើសុំ ប្រវត្តិរូបសង្ខេប និងឯកសារពាក់ព័ន្ធតាមលក្ខខណ្ឌតម្រូវ ស្របតាមបទប្បញ្ញត្តិនៃអនុក្រឹត្យនេះ។

សំណុំឯកសារស្នើសុំផ្ដល់គោរមងារឧកញ៉ា ត្រូវធ្វើជាភាសាខ្មែរ និងដាក់នៅទីស្ដីការគណៈរដ្ឋមន្ត្រី តាមរយៈអគ្គនាយកដ្ឋានឥស្សរិយយសនិងគោរមងារ នៃទីស្ដីការគណៈរដ្ឋមន្ត្រី ដែលជាលេខាធិការដ្ឋានរបស់គណៈកម្មការអន្តរក្រសួងពិនិត្យនិងវាយតម្លៃលើសំណើសុំគោរមងារនិងការបញ្ចប់គោរមងារឧកញ៉ា **គ.ព.វ.គ.**។

**មាត្រា៤ .-**

សំណុំឯកសារស្នើសុំផ្ដល់គោរមងារឧកញ៉ា មានដូចតទៅ៖

| | |
|---|---|
| ១- ពាក្យស្នើសុំ | ចំនួន១(មួយ)ច្បាប់ |
| ២- ប្រវត្តិរូបសង្ខេប (ដោយមានបិទរូបថតថតថ្មី) | ចំនួន១(មួយ)ច្បាប់ |
| ៣- អត្តសញ្ញាណបណ្ណសញ្ជាតិខ្មែរ (ថតចម្លងផ្លូវការ) | ចំនួន១(មួយ)ច្បាប់ |
| ៤- លិខិតឆ្លងដែន (ថតចម្លងផ្លូវការ) | ចំនួន១(មួយ)ច្បាប់ |
| ៥- ព្រះរាជក្រឹត្យស្ដីពីការចូលសញ្ជាតិខ្មែរ (ថតចម្លងផ្លូវការ) | ចំនួន១(មួយ)ច្បាប់ |
| ៦- សេចក្ដីចម្លងសំបុត្រកំណើត (ច្បាប់ដើម) | ចំនួន១(មួយ)ច្បាប់ |
| ៧- សៀវភៅគ្រួសារ/សៀវភៅស្នាក់នៅ (ថតចម្លងផ្លូវការ) | ចំនួន១(មួយ)ច្បាប់ |
| ៨- លិខិតបញ្ជាក់កិរិយាមារយាទ (ច្បាប់ដើម) | ចំនួន១(មួយ)ច្បាប់ |
| ៩- លិខិតថ្កោលទោស មានសុពលភាព(ច្បាប់ដើម) | ចំនួន១(មួយ)ច្បាប់ |
| ១០- វិញ្ញាបនបត្រចុះបញ្ជីសហគ្រាសពាណិជ្ជកម្ម (ថតចម្លង) (ករណីជាសហគ្រិន/ពាណិជ្ជករ/អាជីវករ) | ចំនួន១(មួយ)ច្បាប់ |
| ១១- ប័ណ្ណពន្ធប៉ាតង់ ឆ្នាំចុងក្រោយ (ថតចម្លង) (ករណីជាសហគ្រិន/ពាណិជ្ជករ/អាជីវករ) | ចំនួន១(មួយ)ច្បាប់ |
| ១២- លិខិតអនុញ្ញាតអាជីវកម្មតាមវិស័យពីស្ថាប័នពាក់ព័ន្ធ (ថតចម្លង) (ករណីជាសហគ្រិន/ពាណិជ្ជករ/អាជីវករ) | ចំនួន១(មួយ)ច្បាប់ |
| ១៣- រូបថត ទំហំ៤x៦ (ថតថ្មី) | ចំនួន២(ពីរ)សន្លឹក។ |

**មាត្រា៥ .–**

សំណុំឯកសារស្នើសុំផ្តល់គោរមងារឧកញ៉ា ដូចមានចែងក្នុងមាត្រា៤នៃអនុក្រឹត្យនេះ ត្រូវភ្ជាប់មកជាមួយនូវឯកសារពាក់ព័ន្ធនឹងសមិទ្ធផលជាក់ស្តែងរបស់បេក្ខភាពស្នើសុំគោរមងារ ដែលជាកម្មវត្ថុនៃការវាយតម្លៃក្នុងការផ្តល់គោរមងារឧកញ៉ា ដូចមានកំណត់ក្នុងមាត្រា១៥ មាត្រា១៦ មាត្រា១៧ មាត្រា១៨ មាត្រា១៩ មាត្រា២០ និងមាត្រា២២ និងមាត្រា២៣ នៃអនុក្រឹត្យនេះ។

**មាត្រា៦ .–**

ការដាក់ពាក្យស្នើសុំផ្តល់គោរមងារឧកញ៉ា ត្រូវបង់កម្រៃសេវា។

កម្រៃសេវានៃការដាក់ពាក្យស្នើសុំផ្តល់គោរមងារឧកញ៉ា ត្រូវកំណត់ដោយប្រកាសអន្តរក្រសួងរវាងរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និងរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

កម្រៃសេវាពិនិត្យសំណើសុំផ្តល់គោរមងារឧកញ៉ានិងឯកសារពាក់ព័ន្ធ ត្រូវបង់នៅពេលទទួលបង្កាន់ដៃទទួលពាក្យស្នើសុំ និងមិនអាចប្រគល់ជូនបេក្ខភាពស្នើសុំគោរមងារវិញបានឡើយ។

## ជំពូកទី៣
## បែបបទនិងនីតិវិធីនៃការវាយតម្លៃក្នុងការផ្តល់គោរមងារឧកញ៉ា
### ផ្នែកទី១
### បែបបទនិងនីតិវិធីនៃការវាយតម្លៃ

**មាត្រា៧ .–**

លេខាធិការដ្ឋាន **គ.ព.វ.គ.** ជួយពិនិត្យជាបឋមនូវសំណុំឯកសារស្នើសុំផ្តល់គោរមងារឧកញ៉ា ដែលក្រសួង ស្ថាប័ន ឬសមាគមឧកញ៉ាកម្ពុជា ស្នើមកទីស្តីការគណៈរដ្ឋមន្ត្រី មុនដាក់ជូន **គ.ព.វ.គ.** ពិនិត្យ វាយតម្លៃ និងលើកយោបល់ជូននាយករដ្ឋមន្ត្រី។

ក្នុងករណីសំណុំឯកសារស្នើសុំផ្តល់គោរមងារឧកញ៉ាមានលក្ខណៈមិនគ្រប់គ្រាន់តាមលក្ខខណ្ឌតម្រូវដូចមានចែងក្នុងមាត្រា៤និងមាត្រា៥នៃអនុក្រឹត្យនេះ លេខាធិការដ្ឋាន **គ.ព.វ.គ.** អាចជូនដំណឹងភ្លាម ឬធ្វើលិខិតលាយលក្ខណ៍អក្សរឱ្យធ្វើការកែតម្រូវក្នុងរយៈពេលយ៉ាងយូរ៣(បី)ថ្ងៃ នៃថ្ងៃធ្វើការ។

លេខាធិការដ្ឋាន **គ.ព.វ.គ.** ត្រូវបន្តនីតិវិធីលើសំណើសុំផ្តល់គោរមងារឧកញ៉ា ក្នុងរយៈពេលយ៉ាងយូរ ១៥(ដប់ប្រាំ)ថ្ងៃនៃថ្ងៃធ្វើការ បន្ទាប់ពីថ្ងៃទទួលបានឯកសារកែតម្រូវ។

លេខាធិការដ្ឋាន **គ.ព.វ.គ.** អាចចុះអង្កេតដើម្បីពិនិត្យនិងផ្ទៀងផ្ទាត់សមិទ្ធផលជាក់ស្តែងរបស់បេក្ខភាពស្នើសុំគោរមងារ តាមការសម្រេចរបស់រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និងជាប្រធាន **គ.ព.វ.គ.**។

បែបបទនិងនីតិវិធីនៃការចុះអង្កេត ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រីនិងជាប្រធាន **គ.ព.វ.គ.**។

**មាត្រា៨ .–**

**គ.ព.វ.គ.** មានសមត្ថកិច្ចពិនិត្យ វាយតម្លៃ និងលើកយោបល់ជូននាយករដ្ឋមន្ត្រី លើសំណើសុំនិងវាយតម្លៃក្នុងការផ្តល់គោរមងារឧកញ៉ា។

**គ.ព.វ.គ.** ត្រូវពិនិត្យ វាយតម្លៃ និងលើកយោបល់ជូននាយករដ្ឋមន្ត្រី លើសំណើសុំផ្តល់គោរមងារឧកញ៉ា ដោយផ្អែកតាមលក្ខខណ្ឌនិងលក្ខណសម្បត្តិ គុណបំណាច់ក្នុងការចូលរួមអភិវឌ្ឍនិងកសាងជាតិ ទំហំទឹកប្រាក់នៃអំណោយជាថវិកា តម្លៃសរុបនៃការផ្តល់អំណោយ របកគំហើញបច្ចេកវិទ្យាថ្មីៗ ឬស្នាដៃពិសេស ដែលត្រូវផ្តល់គោរមងារឧកញ៉ាតាមលំដាប់ថ្នាក់ណាមួយ។

ផ្អែកតាមយោបល់ពិនិត្យនិងវាយតម្លៃរបស់ **គ.ព.វ.គ.** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និងជាប្រធាន **គ.ព.វ.គ.** ស្នើសុំការពិនិត្យនិងសម្រេចពីនាយករដ្ឋមន្ត្រី។

នាយករដ្ឋមន្ត្រីតែម្នាក់គត់ មានសិទ្ធិលើកសំណើទូលថ្វាយព្រះមហាក្សត្រក្នុងការស្នើសុំផ្តល់គោរមងារឧកញ៉ា។

ព្រះមហាក្សត្រទ្រង់មានព្រះរាជសិទ្ធិប្រោសព្រះរាជទានគោរមងារឧកញ៉ាដល់រូបវន្តបុគ្គលដែលមានគុណសម្បត្តិ គុណបំណាច់ និងមានស្នាដៃធំធេងក្នុងបុព្វហេតុជាតិ សាសនា ព្រះមហាក្សត្រ។

**មាត្រា៩ ._**

បែបបទនិងនីតិវិធីនៃការស្នើសុំនិងវាយតម្លៃក្នុងការផ្តល់គោរមងារឧកញ៉ា ត្រូវធ្វើឡើងឱ្យបានរួចរាល់ក្នុងក្របខ័ណ្ឌ **គ.ព.វ.គ.** ក្នុងរយៈពេលយ៉ាងយូរ៦០(ហុកសិប)ថ្ងៃនៃថ្ងៃធ្វើការ ដោយពុំរាប់បញ្ចូលករណីឯកសារត្រូវកែតម្រូវ។

## ផ្នែកទី២
## លក្ខណសម្បត្តិដែលត្រូវផ្តល់គោរមងារឧកញ៉ា

**មាត្រា១០ ._**

រូបវន្តបុគ្គលជាប្រជាពលរដ្ឋខ្មែរដែលត្រូវផ្តល់គោរមងារឧកញ៉ា ត្រូវមានលក្ខណសម្បត្តិដូចខាងក្រោម៖

- មានប្រវត្តិរូបច្បាស់លាស់
- មានកិរិយាមារយាទល្អ
- ពុំធ្លាប់ត្រូវបានផ្តន្ទាទោសពីបទឧក្រិដ្ឋឬបទមជ្ឈិមណាមួយ
- ប្រកបមុខរបរស្របច្បាប់។

## ផ្នែកទី៣
## លំដាប់ថ្នាក់គោរមងារឧកញ៉ា

**មាត្រា១១ ._**

គោរមងារឧកញ៉ាមាន៣(បី)លំដាប់ថ្នាក់ ដូចខាងក្រោម៖

- លំដាប់ថ្នាក់ទី១ លោកអ្នកឧកញ៉ា
- លំដាប់ថ្នាក់ទី២ អ្នកឧកញ៉ា
- លំដាប់ថ្នាក់ទី៣ ឧកញ៉ា។

**មាត្រា១២ ._**

គោរមងារឧកញ៉ាតាមលំដាប់ថ្នាក់ ត្រូវផ្តល់ជូនដោយព្រះរាជក្រឹត្យ តាមសំណើរបស់នាយករដ្ឋមន្ត្រី បន្ទាប់ពីមានសេចក្តីស្នើសុំពីរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និងជាប្រធាន **គ.ព.វ.គ.** ផ្អែកតាមយោបល់ពិនិត្យនិងវាយតម្លៃរបស់ **គ.ព.វ.គ.**។

## ជំពូកទី៤
## ការផ្តល់អំណោយ
## ដែលត្រូវផ្តល់គោរមងារឧកញ៉ា

**មាត្រា១៣ .-**

គោរមងារឧកញ៉ាលំដាប់ថ្នាក់ណាមួយ ត្រូវផ្តល់ជូនរូបវន្តបុគ្គលជាប្រជាពលរដ្ឋខ្មែរ ដោយផ្អែកតាមគុណបំណាច់របស់រូបវន្តបុគ្គលម្នាក់ៗ ក្នុងការចូលរួមអភិវឌ្ឍនិងកសាងជាតិ តាមរយៈការផ្តល់អំណោយជាថវិកា និង/ឬការបរិច្ចាគធនធានទ្រព្យសម្បត្តិ សម្ភារៈបរិក្ខារនានាជូនរដ្ឋ ការកសាងហេដ្ឋារចនាសម្ព័ន្ធរូបវន្តនានា ក្នុងនោះមានដូចជា ផ្លូវ ស្ពាន សាលារៀន មន្ទីរពេទ្យ ប្រព័ន្ធធារាសាស្ត្រ វត្តអារាម អគារសាធារណៈ ឬសមិទ្ធផលផ្សេងៗ ជាអត្ថប្រយោជន៍សម្រាប់សង្គមជាតិ ស្របតាមបទប្បញ្ញត្តិនៃអនុក្រឹត្យនេះ។

**មាត្រា១៤ .-**

ថវិកាដែលជាអំណោយ ដូចមានកំណត់ក្នុងមាត្រា១៣នៃអនុក្រឹត្យនេះ ត្រូវមានប្រភពច្បាស់លាស់និងស្របច្បាប់។

ថវិកាដែលជាអំណោយនេះ ត្រូវបង់ចូលគណនីធនាគារនៃធនាគារជាតិនៃកម្ពុជា ឬធនាគារពាណិជ្ជណាមួយដែលគ្រប់គ្រងដោយទីស្តីការគណៈរដ្ឋមន្ត្រី។

## ជំពូកទី៥
## លក្ខខណ្ឌនិងទំហំទឹកប្រាក់នៃការផ្តល់អំណោយ
## ដែលត្រូវផ្តល់គោរមងារឧកញ៉ាតាមលំដាប់ថ្នាក់

**មាត្រា១៥ .-**

ការផ្តល់គោរមងារជាលោកអ្នកឧកញ៉ា ត្រូវអនុវត្តចំពោះគោរមវន្តដែលបានទទួលគោរមងារជាអ្នកឧកញ៉ា យ៉ាងតិច៥(ប្រាំ)ឆ្នាំ មានអាយុយ៉ាងតិច៤៥(សែសិបប្រាំ)ឆ្នាំ និងផ្តល់អំណោយជាថវិកាជូនរដ្ឋ ក្នុងទំហំទឹកប្រាក់ចំនួន ១៦ ០០០ ០០០ ០០០ (ដប់ប្រាំមួយប៊ីលាន) រៀលឡើងទៅ បន្ថែមពីលើសមិទ្ធផលផ្សេងទៀតដែលជាអត្ថប្រយោជន៍សម្រាប់សង្គមជាតិ។

**មាត្រា១៦ .-**

ការផ្តល់គោរមងារជាអ្នកឧកញ៉ា ត្រូវអនុវត្តចំពោះគោរមវន្តដែលបានទទួលគោរមងារជាឧកញ៉ា យ៉ាងតិច៣(បី)ឆ្នាំ និងផ្តល់អំណោយជាថវិកាជូនរដ្ឋ ក្នុងទំហំទឹកប្រាក់ចំនួន ៤ ០០០ ០០០ ០០០(បួនប៊ីលាន)រៀលឡើងទៅ បន្ថែមពីលើសមិទ្ធផលផ្សេងទៀតដែលជាអត្ថប្រយោជន៍សម្រាប់សង្គមជាតិ។

**មាត្រា១៧ .-**

រូបវន្តបុគ្គលជាប្រជាពលរដ្ឋខ្មែរ ដែលត្រូវផ្តល់គោរមងារជាឧកញ៉ា ត្រូវមានអាយុយ៉ាងតិច១៨(ដប់ប្រាំបី)ឆ្នាំ និងត្រូវផ្តល់អំណោយជាថវិកាជូនរដ្ឋ ក្នុងទំហំទឹកប្រាក់ចំនួន ២ ០០០ ០០០ ០០០ (ពីរប៊ីលាន) រៀលឡើងទៅ ឬកសាងសមិទ្ធផលនានាជាអត្ថប្រយោជន៍សម្រាប់សង្គមជាតិ ដែលមានតម្លៃសមមូលនឹងទំហំទឹកប្រាក់ចំនួន ២ ០០០ ០០០ ០០០ (ពីរប៊ីលាន)រៀលឡើងទៅ។

**មាត្រា១៨ .-**

បទប្បញ្ញត្តិក្នុងមាត្រា១៥ មាត្រា១៦ និងមាត្រា១៧នៃអនុក្រឹត្យនេះ មិនអនុវត្តចំពោះគោរមវន្តដែលមានស្នាដៃលើរបកគំហើញនូវបច្ចេកវិទ្យាថ្មីៗណាមួយ ឬស្នាដៃពិសេសដែលមានអត្ថប្រយោជន៍សម្រាប់សង្គមជាតិ ហើយមានការទទួលស្គាល់ជាផ្លូវការពីស្ថាប័នមានសមត្ថកិច្ចជាតិឬអន្តរជាតិ។

**មាត្រា១៩ .-**

ការទទួលបានគោរមងារ ត្រូវធ្វើឡើងតាមលំដាប់ថ្នាក់ ដោយមិនអាចរំលងលំដាប់ថ្នាក់បានឡើយ។

គោរមវន្តទទួលបានគោរមងារជាឧកញ៉ា អាចទទួលបានគោរមងារជាអ្នកឧកញ៉ា ដោយអនុវត្តតាមមាត្រា១៦ នៃអនុក្រឹត្យនេះ។

គោរមវន្តទទួលបានគោរមងារជាអ្នកឧកញ៉ា អាចទទួលបានគោរមងារជាលោកអ្នកឧកញ៉ា ដោយអនុវត្តតាមមាត្រា១៥ នៃអនុក្រឹត្យនេះ។

ទំហំទឹកប្រាក់នៃការផ្តល់អំណោយដែលបានផ្តល់រួចក្នុងលំដាប់ថ្នាក់គោរមងារដែលបានទទួលរួច មិនត្រូវបានរាប់ជាកម្មវត្ថុនៃការស្នើសុំផ្តល់គោរមងារឧកញ៉ាលំដាប់ថ្នាក់ខ្ពស់ជាងលំដាប់ថ្នាក់បច្ចុប្បន្នឡើយ។

**មាត្រា២០ .-**

ទំហំទឹកប្រាក់នៃការផ្តល់អំណោយ តម្លៃសរុបនៃការផ្តល់អំណោយ ឬការបរិច្ចាគធនធានទ្រព្យសម្បត្តិ ដើម្បីយកទៅប្រើប្រាស់ក្នុងការកសាងហេដ្ឋារចនាសម្ព័ន្ធរូបវន្តនានា ត្រូវមានការទទួលស្គាល់ជាផ្លូវការដោយរាជរដ្ឋាភិបាល ឬក្រសួង ស្ថាប័ន ឬរដ្ឋបាលថ្នាក់ក្រោមជាតិ ឬសមាគមកាកបាទក្រហមកម្ពុជា ឬមូលនិធិផ្សេងៗសម្រាប់សង្គមជាតិ ដោយមានការបញ្ជាក់តាមរយៈបណ្ណថ្លែងអំណរគុណ ឬលិខិតលាយលក្ខណ៍អក្សរអំពីទំហំទឹកប្រាក់ជាក់លាក់ និងសមិទ្ធផលជាក់ស្តែង ដែលជាកម្មវត្ថុនៃការវាយតម្លៃផ្តល់គោរមងារឧកញ៉ាតាមលំដាប់ថ្នាក់ណាមួយ។

## ជំពូកទី៦
## របកគំហើញបច្ចេកវិទ្យាថ្មីៗ ឬស្នាដៃពិសេស ដែលត្រូវផ្តល់គោរមងារឧកញ៉ា

**មាត្រា២១ .-**

គោរមងារឧកញ៉ា អាចផ្តល់ជូនរូបវន្តបុគ្គលជាប្រជាពលរដ្ឋខ្មែរ ដោយផ្អែកតាមគុណបំណាច់របស់រូបវន្តបុគ្គលម្នាក់ៗ ក្នុងការចូលរួមអភិវឌ្ឍនិងកសាងជាតិ តាមរយៈរបកគំហើញនូវបច្ចេកវិទ្យាថ្មីៗណាមួយ ឬស្នាដៃពិសេសដែលមានអត្ថប្រយោជន៍សម្រាប់សង្គមជាតិ ស្របតាមបទប្បញ្ញត្តិនៃអនុក្រឹត្យនេះ។

**មាត្រា២២ .-**

របកគំហើញនូវបច្ចេកវិទ្យាថ្មីៗណាមួយ មានជាអាទិ៍ របកគំហើញ ក្នុងវិស័យឧស្សាហកម្ម កសិកម្ម សុខាភិបាល បច្ចេកវិទ្យាព័ត៌មាន វិទ្យាសាស្ត្រកុំព្យូទ័រ ឬវិស័យប្រហាក់ប្រហែល ឬស្នាដៃពិសេស មានជាអាទិ៍ ក្នុងវិស័យសិល្បៈ កីឡា ស្ថាបត្យកម្ម វប្បធម៌ ប្រពៃណី សាសនា ជាអត្ថប្រយោជន៍សម្រាប់សង្គមជាតិ។

**មាត្រា២៣ .-**

របកគំហើញបច្ចេកវិទ្យាថ្មីៗ ឬស្នាដៃពិសេស ដែលជាកម្មវត្ថុនៃការវាយតម្លៃផ្តល់គោរមងារឧកញ៉ា ត្រូវមានការទទួលស្គាល់ជាផ្លូវការពីស្ថាប័នមានសមត្ថកិច្ចជាតិ អន្តរជាតិ ឬតាមរយៈការទទួលបានពានរង្វាន់វិទ្យាសាស្ត្រនានា។

## ជំពូកទី៧
## ការបង់វិភាគទានប្រចាំឆ្នាំ

**មាត្រា២៤ .-**

គោរមវន្ត ត្រូវបង់ប្រាក់វិភាគទានប្រចាំឆ្នាំ ជូនដល់រាជរដ្ឋាភិបាល ដូចខាងក្រោម៖

- ៤០០ ០០០ ០០០ (បួនរយលាន)រៀល ក្នុងមួយឆ្នាំ ចំពោះលោកអ្នកឧកញ៉ា
- ៦០ ០០០ ០០០ (ហុកសិបលាន)រៀល ក្នុងមួយឆ្នាំ ចំពោះអ្នកឧកញ៉ា
- ៣២ ០០០ ០០០ (សាមសិបពីរលាន)រៀល ក្នុងមួយឆ្នាំ ចំពោះឧកញ៉ា។

ក្នុងករណីចាំបាច់ រាជរដ្ឋាភិបាលអាចកំណត់ឡើងវិញនូវទំហំទឹកប្រាក់វិភាគទានប្រចាំឆ្នាំ ចំពោះគោរមវន្តទាំងអស់ ផ្អែកតាមលទ្ធផលនៃការពិនិត្យនិងវាយតម្លៃរបស់ **គ.ព.វ.គ.**។

គោរមវន្តដែលទទួលបានគោរមងារឧកញ៉ាតាមលំដាប់ថ្នាក់ណាមួយ ដោយមានស្នាដៃលើរបកគំហើញនូវបច្ចេកវិទ្យាថ្មីៗណាមួយ ឬស្នាដៃពិសេសដែលមានអត្ថប្រយោជន៍សម្រាប់សង្គមជាតិ ត្រូវបានលើកលែងចំពោះការបង់វិភាគទានប្រចាំឆ្នាំនេះ។

គោរមវន្តដែលជាសមាជិកសមាគមឧកញ៉ាកម្ពុជា ត្រូវបានទទួលការលើកទឹកចិត្ត តាមរយៈការបន្ធូរបន្ថយចំពោះទំហំទឹកប្រាក់វិភាគទានប្រចាំឆ្នាំ តាមការសម្រេចរបស់នាយករដ្ឋមន្ត្រី។

**មាត្រា២៥ ._**

ការបន្ធូរបន្ថយទំហំទឹកប្រាក់វិភាគទានប្រចាំឆ្នាំ ឬការលើកលែងការបង់វិភាគទានប្រចាំឆ្នាំជាករណីពិសេសចំពោះគោរមវន្ត ត្រូវផ្អែកតាមលទ្ធផលនៃការពិនិត្យនិងវាយតម្លៃរបស់ **គ.ព.វ.គ.** និងការសម្រេចរបស់នាយករដ្ឋមន្ត្រី។

**មាត្រា២៦ ._**

ទឹកប្រាក់ដែលបានមកពីការបង់វិភាគទានប្រចាំឆ្នាំ ត្រូវយកទៅប្រើប្រាស់សម្រាប់ផលប្រយោជន៍សង្គមជាតិ តាមការសម្រេចរបស់នាយករដ្ឋមន្ត្រី។

គោរមវន្តទាំងអស់ ត្រូវបង់វិភាគទានប្រចាំឆ្នាំតាមរយៈសមាគមឧកញ៉ាកម្ពុជា។ សមាគមឧកញ៉ាកម្ពុជាត្រូវផ្ទេរវិភាគទានប្រចាំឆ្នាំនេះ ចូលគណនីធនាគារនៃធនាគារជាតិនៃកម្ពុជា ឬធនាគារពាណិជ្ជណាមួយដែលគ្រប់គ្រងដោយទីស្តីការគណៈរដ្ឋមន្ត្រី តាមការសម្រេចរបស់រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និងជាប្រធាន **គ.ព.វ.គ.**។

លេខាធិការដ្ឋាន **គ.ព.វ.គ.** ត្រូវសហការជាមួយសមាគមឧកញ៉ាកម្ពុជា ក្នុងការប្រមូលវិភាគទានប្រចាំឆ្នាំរបស់គោរមវន្ត។

លេខាធិការដ្ឋាន **គ.ព.វ.គ.** ទទួលនិងគ្រប់គ្រងវិភាគទានប្រចាំឆ្នាំតាមនីតិវិធីហិរញ្ញវត្ថុជាធរមាន។

**មាត្រា២៧ ._**

លេខាធិការដ្ឋាន **គ.ព.វ.គ.** មានកញ្ចប់ថវិកាដោយឡែក នៅក្នុងក្របខ័ណ្ឌថវិកាប្រចាំឆ្នាំរបស់ទីស្តីការគណៈរដ្ឋមន្ត្រី ដើម្បីដំណើរការការងាររបស់ខ្លួន។

## ជំពូកទី៨
## បែបបទនិងនីតិវិធីនៃការបញ្ចប់គោរមងារឧកញ៉ា

**មាត្រា២៨ ._**

គោរមងារឧកញ៉ាអាចត្រូវបានបញ្ចប់ ក្នុងករណីណាមួយដូចខាងក្រោម៖

- គោរមវន្តសុំលាលែងពីគោរមងារឧកញ៉ាដោយស្ម័គ្រចិត្ត
- គោរមវន្តមិនបំពេញកាតព្វកិច្ចបង់វិភាគទានប្រចាំឆ្នាំរយៈពេល៣(បី)ឆ្នាំជាប់គ្នា ដោយគ្មានមូលហេតុ
- គោរមវន្តត្រូវបានផ្តន្ទាទោសពីបទឧក្រិដ្ឋ ឬបទមជ្ឈិមណាមួយ
- ត្រូវបានរកឃើញសកម្មភាពណាដែលធ្វើឱ្យប៉ះពាល់កិត្តិយស សីលធម៌ សុជីវធម៌ និងសេចក្តីថ្លៃថ្នូររបស់គោរមងារឧកញ៉ា
- ត្រូវបានរកឃើញថាសំណុំឯកសារស្នើសុំគោរមងារឧកញ៉ារបស់គោរមវន្តមានការក្លែងបន្លំ។

**មាត្រា២៩ .-**

**គ.ព.ទ.គ.** ត្រូវពិនិត្យ វាយតម្លៃ និងលើកយោបល់ជូននាយករដ្ឋមន្ត្រី លើសំណើបញ្ចប់គោរមងារឧកញ៉ា អនុលោមតាមលិខិតបទដ្ឋានគតិយុត្តជាធរមាន។

**មាត្រា៣០ .-**

លេខាធិការដ្ឋាន **គ.ព.ទ.គ.** ជួយ **គ.ព.ទ.គ.** រៀបចំបែបបទបញ្ចប់គោរមងារឧកញ៉ាតាមលំដាប់ថ្នាក់ ស្របតាមមាត្រា២៨នៃអនុក្រឹត្យនេះ។

**មាត្រា៣១ .-**

លេខាធិការដ្ឋាន **គ.ព.ទ.គ.** ជួយ **គ.ព.ទ.គ.** ពិនិត្យ វាយតម្លៃ និងលើកយោបល់ជូន **គ.ព.ទ.គ.** ពិនិត្យសម្រេច ដើម្បីលើកយោបល់ជូននាយករដ្ឋមន្ត្រី លើការបញ្ចប់គោរមងារឧកញ៉ា ចំពោះគោរមវន្តជាមន្ត្រីរាជការស៊ីវិល មន្ត្រីនគរបាលជាតិ និងយោធិន ដែលមានវិសមិតភាពជាមួយគោរមងារឧកញ៉ា ដូចមានចែងក្នុងព្រះរាជក្រឹត្យលេខ នស/រកត/១០២៣/២២៥០ ចុះថ្ងៃទី១១ ខែតុលា ឆ្នាំ២០២៣ ស្តីពីគោរមងារឧកញ៉ា។

**មាត្រា៣២ .-**

គោរមងារឧកញ៉ាត្រូវបញ្ចប់ដោយព្រះរាជក្រឹត្យ តាមសំណើទូលថ្វាយព្រះមហាក្សត្ររបស់នាយករដ្ឋមន្ត្រី ផ្អែកតាមការពិនិត្យនិងវាយតម្លៃរបស់ **គ.ព.ទ.គ.**។

## ជំពូកទី៩
## បទប្បញ្ញត្តិដោយឡែក

**មាត្រា៣៣ .-**

សមាគមឧកញ៉ាកម្ពុជា ជាស្ថាប័នតែមួយគត់ដែលតំណាងឱ្យគោរមវន្តឧកញ៉ាទាំងអស់ក្នុងព្រះរាជាណាចក្រកម្ពុជានិងត្រូវបានទទួលស្គាល់ជាដៃគូរបស់រាជរដ្ឋាភិបាល លើការងារជួយរាជរដ្ឋាភិបាលក្នុងការធ្វើបច្ចុប្បន្នកម្មបញ្ជីឈ្មោះរបស់គោរមវន្តឧកញ៉ាទាំងអស់នៅព្រះរាជាណាចក្រកម្ពុជា និងការងារផ្សេងទៀត ស្របតាមព្រះរាជក្រឹត្យលេខ នស/រកត/១០២៣/២២៥០ ចុះថ្ងៃទី១១ ខែតុលា ឆ្នាំ២០២៣ ស្តីពីគោរមងារឧកញ៉ា។

**មាត្រា៣៤ .-**

គោរមវន្តតាមលំដាប់ថ្នាក់ មានបុព្វសិទ្ធិនិងអត្ថប្រយោជន៍ផ្សេងៗ កំណត់ដោយលិខិតបទដ្ឋានគតិយុត្តដោយឡែក។

**មាត្រា៣៥ .-**

គោរមវន្តដែលបានទទួលការប្រោសព្រះរាជទានគោរមងារឧកញ៉ាតាមលំដាប់ថ្នាក់ ត្រូវស្នើសុំបណ្ណសម្គាល់ឧកញ៉ា ដោយភ្ជាប់មកជាមួយនូវសេចក្តីចម្លងព្រះរាជក្រឹត្យមកទីស្តីការគណៈរដ្ឋមន្ត្រី។

ទីស្តីការគណៈរដ្ឋមន្ត្រី ត្រូវចេញបណ្ណសម្គាល់ឧកញ៉ាជូនដល់គោរមវន្ត ក្នុងរយៈពេលយ៉ាងយូរ៣០ (សាមសិប)ថ្ងៃនៃថ្ងៃធ្វើការ បន្ទាប់ពីទទួលបានសំណើរបស់គោរមវន្ត។

## ជំពូកទី១០
## អន្តរប្បញ្ញត្តិ

**មាត្រា៣៦ .-**

រាល់លិខិតបទដ្ឋានគតិយុត្តទាំងឡាយណាដែលពាក់ព័ន្ធនឹងគោរមងារឧកញ៉ា ត្រូវមានអានុភាពអនុវត្តបន្តរហូតដល់មានលិខិតបទដ្ឋានគតិយុត្តថ្មីមកជំនួសស្របតាមបទប្បញ្ញត្តិនៃអនុក្រឹត្យនេះ។

**មាត្រា៣៧ .-**

គោរមន្តដែលទទួលបានការផ្តល់គោរមងារឧកញ៉ាមុនព្រះរាជក្រឹត្យលេខ នស/រកត/១០២៣/២២៥០ ចុះថ្ងៃទី១១ ខែតុលា ឆ្នាំ២០២៣ ស្តីពីគោរមងារឧកញ៉ា ត្រូវបង់វិភាគទានប្រចាំឆ្នាំក្នុងរយៈពេល៦(ប្រាំមួយ)ខែ បន្ទាប់ពីអនុក្រឹត្យនេះចូលជាធរមាន។

## ជំពូកទី១១
## អវសានប្បញ្ញត្តិ

**មាត្រា៣៨ .-**

អនុក្រឹត្យលេខ៤៣ អនក្រ.បក ចុះថ្ងៃទី២០ ខែមីនា ឆ្នាំ២០១៧ ស្តីពីការកែសម្រួលចំណុចទី១ មាត្រា២ នៃអនុក្រឹត្យលេខ១៥ អនក្រ ចុះថ្ងៃទី៥ ខែមេសា ឆ្នាំ១៩៩៤ និងបទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

**មាត្រា៣៩ .-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីគ្រប់ក្រសួង និងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃ អង្គារ ១៣ រោច ខែ ពិសាខ ឆ្នាំរោង ឆស័ក ព.ស.២៥៦៨

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ៤ ខែ មិថុនា ឆ្នាំ២០២៤

**នាយករដ្ឋមន្ត្រី**

**សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត**

**កន្លែងទទួល៖**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចមហាបវរធិបតីនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តមឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា៣៩
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ